# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុប លទ្ធផលការងារ ឆ្នាំ២០១៦ និងលើកទិសដៅអនុវត្តការងារឆ្នាំបន្ទាប់ របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តកំពត




កិច្ចប្រជុំនេះត្រូវបានប្រារព្ធធ្វើឡើង នាព្រឹកថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦ នៅសាលប្រជុំសាលាខេត្តកំពត ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មនិងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា។

**ឯកឧត្តម ចាន់ ចេស្តា** អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត តាងនាមសមាជិកក្រុមការងារថ្នាក់ជាតិ ទាំងមូលបានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគុណតម្លៃដឹកនាំ និងការចង្អុរបង្ហាញរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ដែលធ្វើឲ្យបញ្ហាប្រឈម ត្រូវបានដោះស្រាយ

ជាបន្តបន្ទាប់ ទាកទងការងារអភិវឌ្ឍន៍មូលដ្ឋាន និងប្រសិទ្ធិភាពនៃការផ្តល់សេវា រដ្ឋបាល និងសេវាសាធារណៈជូនប្រជាពលរដ្ឋ ជាពិសេសការចូលរួម ដោយផ្ទាល់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានក្រុមការងារ ក្នុងការដោះស្រាយជាបន្ទាន់ នូវភាពខ្វះខាតទឹកស្អាត និងទឹកប្រើប្រាស់ ជូនប្រជាពលរដ្ឋនារដូវប្រាំងក្តៅហែង ឆ្នាំ ២០១៦កន្លងមក ការកាត់ដីចំណែករដ្ឋក្រោមការគ្រប់គ្រង របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋ ដើម្បីទទួលបានកម្មសិទ្ធ ស្របច្បាប់ ការធ្វើការវេទិកាសាធារណៈ។

ដោយឡែក សំដៅដោះស្រាយបញ្ហាជាក់ស្តែងតាមវិស័យ មានដូចជា វេទិកាសាធារណៈជាមួយ គ្រូបង្រៀន ជាមួយសហគមន៍អ្នកផលិតអំបិល និងជាមួយនិវត្តជនទូទាំងខេត្តកំពត ។ ក្រៅពីនោះ គឺការសម្រេចចិត្តកែសម្រួលរចនាសម្ព័ន ក្រុមការងារថ្នាក់ជាតិ និងក្រុមជំនួយការ បានជម្រុញ ឲ្យកាន់តែប្រសើឡើងនូវប្រសិទ្ធិភាពការងារ និងសាមគ្គីភាពខ្ពស់។ យោងតាមរបាយការណ៍របស់ លោក ចាន់ ចេស្តា បានបញ្ជាក់ថា ក្រុមការងារ ចុះមូលដ្ឋានខេត្ត និងក្រុង ស្រុក បានចុះធ្វើវេទិកាសាធារណៈ រយៈពេលមួយឆ្នាំកន្លងមក សរុបចំនួន ៨៧ លើក មានការចូលរួមពីក្រុមការងារចំនួន ៣.០២៤ នាក់ និងមានប្រជាពលរដ្ឋចូលរួមចំនួន ១១.០៨៧នាក់ ស្ត្រី ចំនួន ៥.២៥៩នាក់ ដោយប្រមូលបានបញ្ហា សំណូមពរ ចំនួន៤៦០ ករណី ។ ក្នុងនោះ ដោះស្រាយបានចំនួន២៤៥បញ្ហា កំពុងដោះស្រាយចំនួន ១៣៧ បញ្ហា និងមិនទាន់ ដោះស្រាយ ចំនួន ៧៨ បញ្ហា សំណូមពរ ។

មានប្រសាសន៍ នាឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានបង្ហាញនូវការ កោតសរសើរ និងមោទនភាពចំពោះសមាជិក ក្រុមការងារថ្នាក់ជាតិទាំងមូល ដែលបានខិតខំសម្រេច នូវលទ្ធផលផ្លែផ្កា និងសមិទ្ធផលជាក់ស្តែងជាច្រើន ក្នុងរយៈពេលមួយឆ្នាំកន្លងមក ដែលស្តែងចេញ ពីកិច្ចសហការ សាមគ្គីភាពខ្ពស់ និងមានកាទទួលខុសត្រូវ តាមមុខសញ្ញារៀងៗខ្លួន ដែលចាត់ទុកថាជាសមិទ្ធិផលរួម សម្រាប់យើងទាំងអស់គ្នា។ កត្តានេះ ធ្វើឲ្យប្រជាពលរដ្ឋមូលដ្ឋាន កាន់តែមានទំនុកចិត្ត នូវការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានក្រុមការងារ បានណែនាំជាក់ស្តែងមួយចំនួន បន្តខិតខំដោះស្រាយ បញ្ហាដែលនៅសេសសល់ និងសម្រេចជោគជ័យ នូវផែនការទិសដៅបន្ត ។ ក្នុងនោះក្រៅពីធ្វើវេទិការ សាធារណៈ ត្រូវមានពេលវេលាចុះផ្ទាល់ដល់មូលដ្ឋាន រឺលំនៅដ្ឋានប្រជាពលរដ្ឋផ្ទាល់តែម្តង ដើម្បីក្តាប់ បាននូវកង្វល់ បញ្ហាប្រឈម រួមទាំងភាពរីករាយ របស់បងប្អូនប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈ ការសម្រេច និងប្រកាសកន្លងមក ដោយប្រមុខរាជរដ្ឋាភិបាល **សម្តេចតេជោ ហ៊ុន សែន** ដូចជា

គោលនយោបាយដីធ្លី គោលនយោបាយសារពើពន្ធ រួមទាំងការសម្រួលសេវារដ្ឋបាល និងសេវាសាធារណៈ ជាច្រើនទៀត។

គួររំឭកថា គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់រដ្ឋាភិបាល ទើបបានចេញនូវគោលនយោបាយអភិវឌ្ឍន៍ ឃុំ សង្កាត់ របស់ខ្លួន ចំនួន ១៣ ចំណុច សម្រាប់ឆ្នាំ ២០១៧-២០២២ ជាសំខាន់ ដែលចំណុច លេចធ្លោនោះគឺ ការផ្តល់សេវាដោយឥតគិតថ្លៃ ពីការចុះបញ្ជី កំណើត-អាពាហ៍ពិពាហ៍-មរណភាព-សៀវភៅគ្រួសារ-សៀវភៅស្នាក់នៅ-អត្តសញ្ញាណខ្មែរ ។ រីឯ ប្រជាពលរដ្ឋក្រីក្រ និងទទួលបានសេវាព្យាបាល ដោយឥតគិតថ្លៃ តាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋ។ ចំណែកការសំណូមពរ របស់ប្រជាពលរដ្ឋឲ្យបញ្ចុះតម្លៃ ប្រើប្រាស់ទឹកស្អាត យើងបានខិតខំណាស់កន្លងមក និងសូមឲ្យប្រជាពលរដ្ឋ ស្វែងយល់បន្តិចថា ទឹកស្អាត មួយម៉ែត្រគ្រីគុណ តម្លៃ២.០០០រៀល ឬ ២.៥០០ រៀល គឺស្មើនិងទឹក១.០០០ លីត្រ ឬស្មើ និង ០៧ ពាងធំ តើបងប្អូនជួលគេរែកដាក់ពាងបានទេ ក្នុងតម្លៃខាងលើ នៅពេលដែលទឹកស្អាតបណ្តាញដល់ផ្ទះ និងអាចត្រងផឹកបាន។

ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានណែនាំឲ្យរដ្ឋបាលខេត្ត សហការល្អ ជាមួយប្រទេសជិតខាងវៀតណាម ដើម្បីជម្រុញ និងដោះស្រាយបញ្ហាពាណិជ្ជកម្ម តាមព្រំដែន នៃប្រទេសទាំងពីរឲ្យកាន់តែប្រសើរឡើង។




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
កិច្ចប្រជុំ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
កិច្ចប្រជុំ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


អនុវត្តអោយបានម៉ឺងម៉ាត់ នូវកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣
របស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី



